# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សមាគមស្រាវជ្រាវ និង ផ្សព្វផ្សាយច្បាប់ខ្មែរ

លេខ..០១៥.....រ.ប.ក/២០១៣

រាជធានីភ្នំពេញ ថ្ងៃទី០៥...ខែវិច្ឆិកា ឆ្នាំ២០១៣

# របាយការណ៍
# សកម្មភាពប្រចាំខែតុលា ឆ្នាំ២០១៣
# របស់សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ

## I. សេចក្តីផ្តើម

សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ មានគោលបំណងចូលរួមជាវិភាគទានដល់សង្គមកម្ពុជា ក្នុងការអភិវឌ្ឍន៍ប្រព័ន្ធយុត្តិធម៌ និង លើកកំពស់ការសិក្សាស្រាវជ្រាវទៅលើបញ្ហា ដោយយោងទៅលើអត្ថបទ ឬ លិខិតបទដ្ឋានគតិយុត្តិជាតិ និង អន្តរជាតិ តាមរយៈការស្រាវជ្រាវ និងផ្សព្វផ្សាយនូវបណ្តា ឯកសារគតិយុត្តដែលមានក្នុងប្រវត្តិសាស្ត្រ និង ឯកសារគតិយុត្តិថ្មីៗដែលទើបត្រូវបានប្រកាសឲ្យប្រើ និងកំពុងនៅជាធរមាននៅក្នុងសង្គមកម្ពុជានាពេលបច្ចុប្បន្ន។ ស្របតាមគោលបំណងនេះ សមាគមបាន និង កំពុងជួយសម្រួលដល់សាធារណជនទូទៅ មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី អ្នកស្រាវជ្រាវទូទៅ សិស្ស និស្សិត តាមរយៈការផ្តល់ជូនដោយឥតគិតថ្លៃនូវឯកសារគតិយុត្តទាំងឡាយ ដែលសមាគមបានខិតខំប្រឹងប្រែងស្រាវជ្រាវ និងផ្សព្វផ្សាយក្នុងគេទំព័ររបស់ខ្លួន។ ក្នុងអំឡុងពេលនៃខែតុលា ឆ្នាំ២០១៣ កន្លងទៅនេះ សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ បានបន្តនូវសកម្មភាពស្រាវជ្រាវ និងផ្សព្វផ្សាយរបស់ខ្លួន តាមរយៈការស្រាវជ្រាវ និងបញ្ចូលបន្ថែមទៅក្នុងគេហទំព័រជូនដល់សាធារណៈជន ទាញយកដោយឥតគិតថ្លៃនូវឯកសារដែលកំពុងជាតម្រូវការចាំបាច់ ដើម្បីជួយសម្រួលដល់អ្នកស្រាវជ្រាវនៅគ្រប់មជ្ឈដ្ឋាន។

## II. សកម្មភាព និងសមិទ្ធផលការងារ

សកម្មភាព និងសមិទ្ធផលការងារដែលសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរសម្រេចបាន តាមរយៈការស្រាវជ្រាវ និងបញ្ចូលឯកសារគតិយុត្តក្នុងគេហទំព័ររបស់ខ្លួន ក្នុងខែតុលា ឆ្នាំ២០១៣កន្លងទៅនេះ រួមមាន ៖

### ១. វិស័យពាណិជ្ជកម្ម

→ ច្បាប់ស្តីពី សារពើពន្ធ

→ ច្បាប់ស្តីពី វិសោធនកម្មនៃច្បាប់ស្តីពីសារពើពន្ធ

→ ច្បាប់ស្តីពី ស្តង់ដារកម្ពុជា

→ ច្បាប់ស្តីពី សហគ្រាសពាណិជ្ជកម្ម

→ ច្បាប់ស្តីពីវិសោធនកម្មមាត្រា២ និងមាត្រា១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម

→ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពី វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

→ ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា

→ ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

→ ច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម

→ ច្បាប់ស្តីពី ការគ្រប់គ្រងរោងចក្រ និងសិប្បកម្ម

→ ច្បាប់ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាព លើផលិផល ទំនិញ សេវា។

### ២. វិស័យព្រហ្មទណ្ឌ

→ ច្បាប់ស្តីពី ការបង្ការ និងការពន្លត់អគ្គីភ័យ

→ ច្បាប់ស្តីពី សហគមន៍កសិកម្ម

→ ច្បាប់ស្តីពី វិសោធនកម្មមាត្រា២៤៧ មាត្រា៣៦៨ មាត្រា៣៧២ និងមាត្រា៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

→ ច្បាប់ស្តីពីច្បាប់ស្តីពី វិសោធនកម្មមាត្រា៣ មាត្រា២៩ និងមាត្រា៣០ នៃច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម

→ ច្បាប់ស្តីពី ការអនុម័តយល់ព្រមលើពិធីសារបន្ថែម ណាហ្គោយ៉ា កូឡាឡាំពួរ ស្តីពីការទទួលខុសត្រូវផ្នែកច្បាប់ និងសំណងការខូចខាតទៅនឹងពិធីសារកាតាហ្សេណាស្តីពីជីវសុវត្ថិភាព។

### ៣. បទដ្ឋានគតិយុត្តឆ្នាំ២០១២

→ រាជក្រម នស/រកម/០១១២/០០១ ស្តីពី ការប្រកាសឲ្យប្រើច្បាប់ ស្តីពី ការត្រួតពិនិត្យគ្រឿងញៀន ចុះថ្ងៃទី០២ ខែមករា ឆ្នាំ២០១២

→ ព្រះរាជក្រម នស/រកម/០១១២/០០៤ ស្តីពី ការប្រកាសឲ្យប្រើច្បាប់ ស្តីពីលទ្ធកម្ម សាធារណៈ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១២

→ ព្រះរាជក្រម នស/រកម/០១១២/០០៥ ស្ដីពី ការប្រកាសឲ្យប្រើច្បាប់ ស្ដីពី ការគ្រប់គ្រងថ្នាំកសិកម្ម និង ជីកសិកម្ម ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

**៤. បទដ្ឋានគតិយុត្តឆ្នាំ២០១១**

→ ព្រះរាជក្រម នស/រកម/០១១១/០០១ ស្ដីពី ការប្រកាសឲ្យប្រើច្បាប់ ស្ដីពី ការអនុម័តយល់ព្រមលើកិច្ចព្រមព្រៀងស្ដីពីបត្យាប័នរវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រ កម្ពុជា និងរដ្ឋាភិបាលនៃសាធារណរដ្ឋកូរ៉េ ចុះថ្ងៃទី០៦ ខែមករា ឆ្នាំ២០១១

→ ព្រះរាជក្រម នស/រកម/១២១១/០០២០ ស្ដីពីការប្រកាសឲ្យប្រើច្បាប់ស្ដីពីការគ្រប់គ្រងអាស៊ីតខ្លាំង ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១១

→ ព្រះរាជក្រម នស/រកម/១២១១/០០២១ ស្ដីពីការប្រកាសឲ្យប្រើច្បាប់ស្ដីពីពន្ធនាគារ ចុះថ្ងៃទី ២១ ខែធ្នូ ឆ្នាំ២០១១

→ ព្រះរាជក្រឹត្យ នស/រកត/០៦១១/៦៣០ ស្ដីពីការបន្ថយរយៈពេលទទួលរងទោសនិង លើកលែងទោសឲ្យទណ្ឌិតដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមកចំនួន ១២៧ នាក់ ចុះថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១១

→ ព្រះរាជក្រឹត្យ នស/រកត/០៩១១/៩០៤ ស្ដីពីការលើកលែងទោសឲ្យទណ្ឌិតចំនួន ០៥ នាក់ ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ២០១១

→ ព្រះរាជក្រឹត្យ នស/រកត/១២១១/១០៧៦ ស្ដីពី ការបន្ថយរយៈពេលទទួលរងទោសឲ្យទណ្ឌិតចំនួន ២៧៧ នាក់ និងលើកលែងទោសឲ្យទណ្ឌិតចំនួន ៩១នាក់ដែលបានខិតខំកែប្រែខ្លួនបានល្អក្នុងរយៈពេលរងទោសក្នុងពន្ធនាគារកន្លងមក ចុះថ្ងៃទី ០៩ ខែ ធ្នូ ឆ្នាំ ២០១១។

**៥. បទដ្ឋានគតិយុត្តឆ្នាំ១៩៩៥**

→ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤២ ស្ដីពីការបន្ថយទោសទណ្ឌិត ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៥

→ ព្រះរាជក្រឹត្យលេខ នស/រកត/០៤៩៥/៤៤ ស្ដីពីការលើកលែងទោសទណ្ឌិត ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៥

→ ព្រះរាជក្រឹត្យលេខ ន/ស/រកត/០៥៩៥/៤៦ ស្ដីពីការបន្ថយទោស ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ១៩៩៥

→ អនុក្រឹត្យ លេខ ៦២ អនក្រ.បក ស្ដីពីការប្រើប្រាស់អាវុធជាតិផ្ទុះគ្រប់ប្រភេទ ចុះថ្ងៃទី៣១ ខែកក្កដា ឆ្នាំ១៩៩៥។

**៦. ឯកសារស្រាវជ្រាវ**

→ ទ្រព្យសម្បត្តិទទួលខុសត្រូវក្នុងនីតិវិធីអនុវត្តដោយបង្ខំ។

## III. សេចក្តីសន្និដ្ឋាន

ក្នុងខែតុលានេះ សមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ បានបន្តសកម្មភាពរបស់ខ្លួន ដោយសម្រេចបាននូវសមិទ្ធផលយ៉ាងច្រើន សម្រាប់បម្រើ និងបំពេញសេចក្តីត្រូវការរបស់សាធារណជនទូទៅ ជាពិសេស មន្ត្រីរាជការ ចៅក្រម ព្រះរាជអាជ្ញា ក្រឡាបញ្ជី មេធាវី អ្នកស្រាវជ្រាវទូទៅ សិស្ស និស្សិត ដែលសុទ្ធសឹងជាអ្នកអនុវត្ត សិក្សា និងស្រាវជ្រាវ អំពីបញ្ហានានា ដោយផ្អែកលើបទដ្ឋានគតិយុត្តជាតិ និងអន្តរជាតិ។ តាមរយៈការផ្តល់ជូនដោយឥតគិតថ្លៃនូវឯកសារគតិយុត្តទាំងឡាយដែលមានក្នុងគេហទំព័ររបស់ខ្លួន សមាគមសង្ឃឹមថា ការរៀបចំ និងការបញ្ចូលនូវឯកសារពាក់ព័ន្ធនឹងការស្រាវជ្រាវ នឹងមានភាពកាន់តែងាយស្រួលសម្រាប់សាធារណជនទាំងឡាយ និងជាការចូលរួមចំណែកក្នុងការអភិវឌ្ឍន៍វិស័យគតិយុត្តឲ្យមានការរីកចម្រើនមួយកម្រិតបន្ថែមទៀត។ ឈរលើស្មារតីទទួលខុសត្រូវខ្ពស់ ក្នុងនាមជាសមាគមដែលមិនមានទិសដៅផ្សព្វផ្សាយច្បាប់ ដោយមិនរកប្រាក់ចំណេញ ថ្នាក់ដឹកនាំ និងសមាជិកទាំងអស់នៃសមាគមស្រាវជ្រាវ និងផ្សព្វផ្សាយច្បាប់ខ្មែរ នឹងខិតខំប្រឹងប្រែងជម្រុញនូវសកម្មភាពស្រាវជ្រាវ និងផ្សព្វផ្សាយ ដើម្បីធានាឲ្យបាននូវភាពកាន់តែសម្បូរបែបក្នុងគេទំព័ររបស់ខ្លួន។

**ប្រធានសមាគម**

**សុខ ប៊ុនឃឿន**